រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ២០១៦

**ឯកឧត្តម ដូណាល់ដ៍ ត្រាំ**
**ប្រធានាធិបតីជាប់ឆ្នោត**
**នៃសហរដ្ឋអាមេរិក**

**<u>រដ្ឋធានីវ៉ាស៊ីនតោន</u>**

*ឯកឧត្តមប្រធានាធិបតីជាប់ឆ្នោត*

តាងនាមអោយរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ខ្ញុំសូមសំដែងនូវក្តីអំណរសាទរអស់ពីដួងចិត្តជូនចំពោះឯកឧត្តម ក្នុងឱកាសដែលឯកឧត្តមត្រូវបានជាប់ឆ្នោតជាប្រធានាធិបតីនៃសហរដ្ឋអាមេរិក។ ខ្ញុំសូមប្រសិទ្ធិពរជ័យជូនឯកឧត្តម សូមឯកឧត្តមទទួលបានជ័យជំនះក្នុងការបំពេញបេសសកម្ម និងការទទួលខុសត្រូវដ៏ឧត្តុង្គឧត្តមរបស់ឯកឧត្តម។

ខ្ញុំមានជំនឿថា ការប្រគល់ទំនុកចិត្តរបស់ប្រជាពលរដ្ឋសហរដ្ឋអាមេរិកជូនចំពោះឯកឧត្តម គឺជាការលើកទឹកចិត្តដល់ឯកឧត្តមក្នុងការខិតខំប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីលើកកំពស់បន្ថែមទៀតនូវ សន្តិភាព ស្ថិរភាព ការអភិវឌ្ឍ សន្តិសុខ និងវិបុលភាពនៅក្នុងសកលលោកទាំងមូល។

ខ្ញុំសូមឆ្លៀតឱកាសដ៏ឧឡារិកនេះ សូមអះអាងជូនឯកឧត្តមថា ព្រះរាជាណាចក្រនិងប្រជាជនកម្ពុជានៅតែប្តេជ្ញាចិត្តចូលរួមនៅក្នុងកិច្ចប្រឹងប្រែងជាមួយរដ្ឋាភិបាលនិងប្រជាជនអាមេរិក ក្នុងការលើកកម្ពស់បន្ថែមទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រទេសយើងទាំងពីរ លើគ្រប់វិស័យដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមក ទាំងនៅកម្រិតទ្វេភាគី និងពហុភាគី។

ខ្ញុំរីករាយនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយឯកឧត្តម មិនត្រឹមតែអភិវឌ្ឍន៍ទំនាក់ទំនងប្រទេសយើងទាំងពីរអោយកាន់តែជិតស្និទ្ធប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប្រឹងប្រែងរួមគ្នាដើម្បីលើកកម្ពស់បុព្វហេតុដ៏ធំធេងដើម្បីសន្តិភាព ស្ថិរភាព និងវិបុលភាពរបស់ប្រជាជាតិទាំងអស់។

សូមឯកឧត្តមទទួលនូវការរាប់អានពីខ្ញុំ។

**ហ៊ុន សែន**